LOOKING AT LIFE

# តើខ្ញុំជា មនុស្សល្អឬ?





# តើខ្ញុំជា
# មនុស្សល្អឬ?

**ដាវីឌគិតថា ខ្លួនគាត់ជាមនុស្សល្អ។** គាត់បានបំពេញករណីកិច្ចជាកូនល្អ ដែលមានភាពជិតស្និទ្ធចំពោះឪពុកម្ដាយ និងបងប្អូនរបស់គាត់ ហើយមិត្តរួមការងារ និងមិត្តភក្តិរបស់គាត់ ក៏ចូលចិត្តគាត់ផងដែរ។ ក្នុងចំណោមពួកគេ មានអ្នកខ្លះថែមទាំងបានហៅគាត់ថា "ដាវីឌជាអ្នកបរិសុទ្ធ" ព្រោះគាត់មិនដែលឆេវឆាវ ហើយក៏មិនដែលរអ៊ូរទាំ ទោះមានរឿងអ្វីកើតឡើងក៏ដោយ។

ប៉ុន្តែ ជាញឹកញាប់ ដាវីឌឆ្ងល់ថា តើខ្លួនគាត់ជាមនុស្សល្អមែនឬ? គាត់ដឹងថា គាត់មានចំណុចខ្វះខាតជាច្រើន គឺមិនល្អឥតខ្ចោះទេ។ គាត់ងាយនឹងបាត់បង់ការអត់ធ្មត់ ហើយជាញឹកញាប់ គាត់ខឹងយ៉ាងខ្លាំង ចំពោះអ្នកណាដែលធ្វើឲ្យគាត់ទ្រាំលែងបាន។ ទោះជាយ៉ាងណាក៏ដោយ ដោយសារធម្មជាតិរបស់គាត់ជាមនុស្សស្ងប់ស្ងាត់ នោះតាមធម្មតា គាត់បានលាក់ទុកអារម្មណ៍របស់គាត់មិនឲ្យអ្នកណាដឹងឡើយ។ "ហេតុនេះហើយ" គាត់ឆ្ងល់ថា "តើខ្ញុំពិតជាមនុស្សល្អមែនទេ?"

មនុស្សភាគច្រើនចង់ធ្វើជាមនុស្សល្អ។ វាហាក់ដូចជារឿងធម្មតា ឬជាសុភាវគិតរបស់មនុស្ស ដែលចង់ធ្វើជាមនុស្សល្អ។ តើហេតុអ្វីយើងចង់ធ្វើជាមនុស្សល្អ? ប្រហែលមកពីយើងមានបំណងចិត្តពីកំណើត ដែលចង់នាំសេចក្តីសុខ និងចង់ធ្វើល្អចំពោះអ្នកដទៃ ព្រមទាំងចង់ឲ្យពិភពលោកកាន់តែមានភាពល្អប្រសើរឡើង។ ពុំនោះទេ តាំងពីក្មេងមក យើងប្រហែលជាបានទទួលការអប់រំណែនាំឲ្យរស់នៅជាមនុស្សល្អ។ ហើយយើងក៏ប្រហែលជាបានឮគេនិយាយជាញឹកញាប់ថា “ធ្វើល្អបានល្អ”។ ពោលគឺគេបង្រៀនយើងថា យើងនឹងមានសុភមង្គល និងភាពសប្បុរសប្បាយ ពេលដែលយើងរស់នៅជាមនុស្សល្អ ហើយថែមទាំងជួបរឿងល្អៗជាច្រើន បន្ទាប់ពីយើងស្លាប់ទៅ។

ប៉ុន្តែ តើនរណាជាមនុស្ស “ល្អ”? តើការរស់នៅជាមនុស្ស “ល្អ” មានន័យយ៉ាងណាចំពោះយើង? ឥឡូវនេះ សូមយើងស្វែងយល់អំពីអត្ថន័យរបស់ពាក្យនេះ ដូចតទៅ។ អ្នកខ្លះយល់ថា មនុស្សល្អគឺជាអ្នកដែលធ្វើអ្វីដែល “ត្រឹមត្រូវ” តាមសតិសម្បជញ្ញៈរបស់ខ្លួន។ គាត់ស្គាល់ភាពត្រឹមត្រូវ ធ្វើអំពើល្អ និងគោរពចាស់ទុំជាដើម។ អ្នកផ្សេងទៀតយល់ថា មនុស្សល្អជាអ្នកដែលគោរពច្បាប់ និងក្រមសីលធម៌ផ្សេងៗ ដោយមិនលួចទ្រព្យសម្បត្តិ ឬសម្លាប់ជីវិតអ្នកដទៃ ហើយរស់នៅ ក្នុងជីវិត

មួយ ដែលគេគោរព និងឲ្យតម្លៃ។

តាមនិយមន័យទាំងនេះ យើងឃើញថា ជាទូទៅមនុស្សជឿថា ដើម្បីក្លាយជាមនុស្សល្អ ទីមួយ : យើងត្រូវរស់នៅ តាមសតិសម្បជញ្ញៈរបស់យើង ហើយទីពីរ : យើងត្រូវគោរពច្បាប់ និងក្រមសីលធម៌របស់សង្គម។ ឥឡូវនេះ សូមយើងសិក្សាឲ្យស៊ីជម្រៅ អំពីនិយមន័យនេះ។

## សម្បជញ្ញៈ និងក្រមសីលធម៌ :

### តើសម្បជញ្ញៈនិងក្រមសីលធម៌របស់យើងល្អគ្រប់គ្រាន់ឬទេ?

**សម្បជញ្ញៈរបស់យើង** ឬការដឹងនៅក្នុងចិត្តថា អ្វីល្អ ហើយអ្វីអាក្រក់ គឺជា "អ្នកចង្អុលទិសដៅ" ផ្នែកសីលធម៌ក្នុងជីវិតយើង។ វាជួយឲ្យយើងដឹងភាពខុសគ្នារវាងខុស និងត្រូវ ហើយនាំយើងទៅរកអ្វីដែលត្រូវ។

ទោះជាយ៉ាងណាក៏ដោយ តើអ្នកដែលឆ្ងល់ទេថា សម្បជញ្ញៈរបស់យើង មានប្រភពមកពីណា? តើសម្បជញ្ញៈរបស់យើងដឹងខុសដឹងត្រូវ ដោយផ្អែកទៅលើអ្វី? តើវាជាអ្វីដែលយើងមានពីកំណើត ឬវាអាចទទួលឥទ្ធិពលពីការអប់រំ ប្រពៃណី វប្បធម៌ ឬគោលតម្លៃនៃសង្គមក្នុងពេលបច្ចុប្បន្ន? ហេតុនេះហើយបានជា មនុស្សយើងមានសម្បជញ្ញៈខុសៗគ្នា ខណៈពេលដែលមនុស្សភាគច្រើនអាចយល់ស្រប ចំពោះក្រមសីលធម៌ជាទូទៅ។

កាលខ្ញុំនៅក្មេង ពួកក្មេងទំនើងមួយក្រុមធ្លាប់វាយធ្វើបាបខ្ញុំ នៅកន្លែងចតឡាន។ ពួកគេបានប្លន់យកលុយខ្ញុំ ហើយដាល់ខ្ញុំ រួចផ្តួលខ្ញុំទៅលើដី។ ទោះជាយ៉ាងណាក៏ដោយ មុនពេលពួកគេចាកចេញទៅ ក្នុងចំណោមពួកគេ មានម្នាក់បានបោះលុយបីបួនកាក់ មកលើខ្ញុំ ដោយនិយាយថា "លុយនេះ សម្រាប់ឲ្យឯងជិះឡានក្រុងទៅផ្ទះវិញ។ យើងក៏មានសម្បជញ្ញៈដែរ មែនទេ?" ពេលដែលខ្ញុំនៅដេកដួលនៅលើដីនៅឡើយ ខ្ញុំពិបាកនឹងយល់ស្របនឹងទស្សនៈគាត់ណាស់។

ខ្ញុំក៏ធ្លាប់អានរឿងរបស់អ្នកជួញគ្រឿងញៀនម្នាក់។ ពេលប៉ូលីសចាប់ខ្លួនគាត់ គាត់និយាយថា គាត់ក៏ជាមនុស្សដែលមានសម្បជញ្ញៈដែរ។ គាត់មិនបានបដិសេធថា គាត់មិនបានជួញដូរគ្រឿងញៀននោះទេ តែគាត់បានប្រកែកថា គាត់មិនបានលួចទ្រព្យសម្បត្តិអ្នកដទៃ ឬសម្លាប់មនុស្សឡើយ ដូចនេះ គាត់ថា គាត់ "មិនមែនជាមនុស្សអាក្រក់ទេ"។

មនុស្សភាគច្រើននឹងនិយាយថា ក្មេងទំនើង និងអ្នកជួញដូរគ្រឿងញៀនក៏មានចំណុចល្អដែរ តែពួកគេបានបំពានក្រមសីលធម៌ ដែលធំជាងក្រមសីលធម៌របស់ពួកគេ។ តែពួកគេពិតជាជឿថា ខ្លួនឯងជាមនុស្ស "ល្អ" ដោយផ្អែកទៅលើសម្បជញ្ញៈរបស់ពួកគេ។ ដូចនេះ មនុស្សម្នាក់ៗបានឲ្យនិយមន័យខុសៗគ្នា សម្រាប់ពាក្យ

"មនុស្សល្អ"។ ដោយសារសម្បជញ្ញៈរបស់យើង មិនល្អឥតខ្ចោះ នោះនិយមន័យរបស់ពាក្យ "មនុស្សល្អ" ដែលយើងម្នាក់ៗបានឲ្យខុសៗគ្នា ក៏មិនត្រូវទាំងស្រុងដែរ។ ហេតុនេះហើយ បានជាប្រទេស និងសង្គមភាគច្រើន ត្រូវការច្បាប់ និងក្រមសីលធម៌។

ទោះច្បាប់ និងបទបញ្ញាត្រូវបានអនុវត្ត ដោយអ្នកមានសមត្ថកិច្ច ឬអនុវត្តដោយសហគមន៍ណាមួយក្តី ច្បាប់ និងក្រមសីលធម៌បានជួយឲ្យមានសណ្តាប់ធ្នាប់ក្នុងសង្គម ដោយធានាថា យើងអាចរស់នៅជាមួយគ្នាដោយសុខសាន្ត ទោះបីជាយើងមានរបៀបរស់នៅ និងក្រមសីលធម៌ខុសគ្នាក៏ដោយ។

ប្រទេសជាច្រើននៅក្នុងពិភពលោក បានបង្កើតច្បាប់ដូចៗគ្នាជាច្រើន។ ឧទាហរណ៍ ការបោកប្រាស់ លួច ឬសម្លាប់ គឺជាអំពើឧក្រិដ្ឋ នៅក្នុងប្រទេសភាគច្រើន។ ប៉ុន្តែ ច្បាប់មួយចំនួនត្រូវបានបង្កើតមក ដោយផ្អែកទៅលើមតិភាគច្រើន នៅក្នុងប្រទេសនីមួយៗ។ ជាក់ស្តែងក្នុងប្រទេសខ្ញុំ គេបានដាក់ទោសមនុស្សមួយចំនួន ពីបទស្លៀកពាក់ខោអាវរឹបរាង ក្នុងទីសាធារណៈ។ នៅប្រទេសផ្សេង គេទទួលយកការស្លៀកពាក់ដូចនេះ តែប្រទេសខ្ញុំមិនអាចទទួលយកបាន ដោយសារមានប្រពៃណីដែលតឹងរឹងជាង។



ច្បាប់និងក្រមសីលធម៌របស់មនុស្សភាគច្រើន ត្រូវបានបង្កើតមក ដោយផ្អែកទៅលើជំនឿរបស់មនុស្ស

សរុបមក ច្បាប់ និងក្រមសីលធម៌ភាគច្រើន ត្រូវបានមនុស្សបង្កើតមក ដោយផ្អែកទៅលើជំនឿរបស់មនុស្ស ដែលមានសម្បជញ្ញៈ ឬមតិភាគច្រើនខុសៗគ្នា។ ច្បាប់ និងក្រមសីលធម៌ ក៏មានភាពខុសប្លែកពីគ្នា ដោយសារវប្បធម៌របស់យើង ហើយថែមទាំងមានការផ្លាស់ប្តូរទៅតាមសម័យកាល គឺមិនខុសពីសម្បជញ្ញៈរបស់យើងឡើយ។ បានសេចក្តីថា ការអ្វីដែលយើងទទួលស្គាល់ថា "ល្អ" ផ្អែកទៅលើច្បាប់ ឬក្រមសីលធម៌ គឺមិន "ល្អ" គ្រប់ពេលវេលា និងគ្រប់ទីកន្លែងនោះឡើយ។ បើសិនជានិយមន័យនៃពាក្យ "មនុស្សល្អ" ស្រេចតែលើទស្សនៈផ្ទាល់ខ្លួនរបស់មនុស្ស ហើយមិនមានភាពឥតខ្ចោះ តើធ្វើដូចម្តេចឲ្យយើងអាចក្លាយជាមនុស្ស "ល្អ"ពិតប្រាកដ?

## ពេលដែលនិយមន័យនៃពាក្យ "មនុស្សល្អ" ស្រេចតែលើទស្សនៈផ្ទាល់ខ្លួនរបស់មនុស្ស

សូមយើងចំណាយពេលគិតថា តើមានអ្វីកើតឡើងពេលដែលយើងឲ្យនិយមន័យខុសៗគ្នា សម្រាប់ពាក្យ "មនុស្សល្អ"។ បញ្ហានេះនឹងនាំមកនូវផលវិបាកដូចតទៅ:

**ទីមួយ : យើងនឹងជ្រើសរើសយកទស្សនៈរបស់ខ្លួនឯង។** ពេលណាមនុស្សក្នុងសង្គម មានទស្សនៈខុសៗគ្នាអំពីអ្វីដែលត្រូវ និងអ្វីដែលខុស នោះមនុស្សម្នាក់ៗនឹង

ពឹងផ្អែកទៅលើការយល់ដឹងរបស់ខ្លួន អំពីក្រមសីលធម៌។ ទោះជាយ៉ាងណាក៏ដោយ មនុស្សទាំងអស់សុទ្ធតែមានសម្បជញ្ញៈដែលមិនល្អឥតខ្ចោះ ដូចនេះ វិធីសាស្ត្រនេះមិនសូវល្អប៉ុន្មានទេ។ ក្មេងទំនើងដែលបានប្លន់ខ្ញុំកាលពីថ្ងៃនោះ ប្រហែលជាគិតថា ពួកគេមានចិត្តល្អចំពោះខ្ញុំ ដោយបានទុកលុយឲ្យខ្ញុំខ្លះ សម្រាប់ជិះឡានក្រុងទៅផ្ទះ។ ដូចនេះ ពេលដែលយើងម្នាក់ៗ សុទ្ធតែមានស្តង់ដា ឬទស្សនៈខុសៗគ្នា អំពីអ្វីដែលត្រូវ អ្វីដែលខុស នោះយើងមិនដឹងថា នរណាជាមនុស្សល្អពិតប្រាកដឡើយ។

**ទីពីរ : យើងនឹងយកគំនិតខ្លួនឯងជាធំ។** បើសិនជាការសម្រេចចិត្តរបស់យើង មិនផ្អែកទៅលើសេចក្តីពិតទេ នោះយើងងាយនឹងយកបំណងចិត្ត និងតម្រូវការរបស់ខ្លួនឯង និងតម្រូវការរបស់មនុស្សជាទីស្រឡាញ់ជាធំ ឬជាអទិភាព ហើយបង្កើតក្រមសីលធម៌ផ្ទាល់ខ្លួន ដើម្បីសម្រេចគោលដៅ ឬបំណងរបស់យើង។ ឧទាហរណ៍ អ្នកជួញគ្រឿងញៀនប្រហែលជាគិតថា ការលក់គ្រឿងញៀនជាទង្វើរដ៏ត្រឹមត្រូវ ព្រោះគាត់ត្រូវការលុយ ដើម្បីផ្គត់ផ្គង់គ្រួសារគាត់។

**ទីបី : យើងនឹងបើកដៃឲ្យខ្លួនឯងធ្វើអ្វីតាមចិត្ត។** បើសិនជាយើងប្រកាន់យកនូវក្រុមសលធម៌ ដែលមិនល្អឥតខ្ចោះទេ នោះយើងងាយនឹងបត់បែន ឬផ្លាស់ប្តូរក្បួន



*ពេលដែលយើងម្នាក់ៗ សុទ្ធតែមានស្តង់ដា ឬទស្សនៈខុសៗគ្នា អំពីអ្វីដែលត្រូវ អ្វីដែលខុស នោះយើងមិនដឹងថា នរណាជាមនុស្សល្អពិតប្រាកដឡើយ។*

ខ្នាតរបស់យើង ឬបន្ថែមបន្ថយស្តង់ដារបស់យើង។ ពេលយើងធ្វើអ្វីខុស យើងនឹងដោះសារ ដោយយកលេសថា វាជាកំហុសដែល "តូចជាង" និងទម្លាក់កំហុសទៅលើ "ចរិយាសម្បត្តិ ដែលមិនល្អឥតខ្ចោះ" ឬចាត់ទុកវាជាករណីលើកលែង ដោយសារ "កាលៈទេសៈ"ខុសគ្នាជាដើម។

សូមយើងស្រមៃថា តើនឹងមានអ្វីកើតឡើង ពេលដែលយើងបង្កើតក្រមសីលធម៌ដោយខ្លួនឯង ឬបន្ថែមបន្ថយវាតាមការនឹកឃើញរបស់ខ្លួនឯង។ យើងនឹងដឹងថា យើងមិនគ្រាន់តែមិនអាចធ្វើជាមនុស្សល្អពិតប្រាកដប៉ុណ្ណោះទេ តែយើងក៏ពិបាករស់នៅ ដោយសុខដុមជាមួយអ្នកដទៃទៀតផង។ តើវានឹងមានផលប៉ះពាល់អ្វីខ្លះមកលើជីវិតយើង? ឧបមាថា យើងកំពុងតែសង់ផ្ទះមួយខ្នង តាមតែចិត្តខ្លួនឯង គឺមិនផ្អែកទៅលើស្តង់ដាដ៏ត្រឹមត្រូវ សម្រាប់ការសង់ផ្ទះ។ យើងអាចប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ហើយប្រកាស់ថា សំណង់របស់យើងមានភាពរឹងមាំណាស់ ប៉ុន្តែ វានឹងមិនមានសុវត្ថិភាព សម្រាប់ឲ្យយើងចូលនៅឡើយ។ ទោះយើងបានព្យាយាម ឬមានចិត្តឆេះឆួលយ៉ាងណាក៏ដោយ ការសាងសង់ ដោយខ្វះការយល់ដឹងអំពីបច្ចេកទេស នៃការសាងសង់ នឹងនាំមកនូវបរាជ័យ។


តើនរណាមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់
ដើម្បីកំណត់ថា អ្វីល្អ អ្វីអាក្រក់?

យើងម្នាក់ៗ គឺជាចំណុចកណ្ដាលនៃបញ្ហារបស់យើង។ យើងពិតជាចង់ និងព្យាយាមរស់នៅជាមនុស្សល្អ តែសតិសម្បជញ្ញៈរបស់យើងមិនល្អឥតខ្ចោះ ហើយយើងក៏មានលក្ខណៈពីកំណើត ដែលមានបាប និងមានភាពអាត្មានិយម ដែលងាយនឹងចាញ់ការល្បួងឲ្យធ្វើការអាក្រក់។ សូម្បីតែស្តង់ដានៃសេចក្តីល្អរបស់យើង ក៏មិនល្អឥតខ្ចោះដែរ ព្រោះយើងជាអ្នកបង្កើតវាមកដោយខ្លួនឯង។ ហេតុនេះហើយបានជាមនុស្សជាច្រើន ក៏ដូចជាដាវីឌ មិនដឹងច្បាស់ថា ខ្លួនឯងពិតជាមនុស្សល្អឬអត់ទេ។ តាមសុភាវគិតរបស់យើង យើងដឹងថា យើងមិនល្អគ្រប់គ្រាន់ទេ។

ប៉ុន្តែ តើយើងត្រូវធ្វើដូចម្តេច? តើយើងអាចធ្វើជាមនុស្សល្អពិតប្រាកដដោយរបៀបណា បើសិនជាសម្បជញ្ញៈ និងក្រមសីលធម៌របស់យើង មិនអាចឲ្យយើងពឹងផ្អែកបាន ហើយការដែលយើងខិតខំរស់នៅជាមនុស្សល្អនៅមានចំណុចខ្វះខាតកាន់តែច្រើន?

## គំរូដ៏ល្អឥតខ្ចោះ សម្រាប់ "មនុស្សល្អ"

**ហេតុមកដល់ចំណុចនេះ យើងបានស្វែងយល់អំពីអត្ថន័យនៃពាក្យ "មនុស្សល្អ" តាមទស្សនៈដែលមនុស្សមានខុសៗគ្នា។** យើងប្រហែលជាចង់គិតអំពីបញ្ហានេះ តាមរបៀបខុសពីនេះ ដោយចោទសួរថា តើនរណាមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់ ដើម្បីកំណត់ថា អ្វីល្អ អ្វី

អាក្រក់?

ឥឡូវនេះ សូមយើងគិតអំពីបន្ទាត់មែត្រ ដែលយើងប្រើ ដើម្បីវាស់ប្រវែងរបស់វត្ថុផ្សេងៗ។ បន្ទាត់ម៉ែត្រគឺជា "ស្តង់ដា" ដែលយើងអាចមើលឃើញ ដែលយើងអាចពឹងផ្អែកបាន ដើម្បីវាស់ឲ្យដឹងថា តុរបស់យើងមានប្រវែងប៉ុន្មានម៉ែត្រ។ តែយើងប្រហែលមិនដឹងទេថា សូម្បីតែបន្ទាត់ម៉ែត្រក៏មិនតែងតែអាចឲ្យយើងពឹងផ្អែកបានជានិច្ចដែរ។ បន្ទាត់ម៉ែត្រខ្លះវាស់ឃើញប្រវែង ១ម៉ែត្រ ហើយខ្លះទៀតវាស់ឃើញប្រវែង ១,០៥ម៉ែត្រ។ តើធ្វើដូចម្តេចឲ្យយើងដឹងថា បន្ទាត់ម៉ែត្រមួយណាត្រឹមត្រូវ? តើធ្វើដូចម្តេច ឲ្យយើងអាចដឹងថា រង្វាស់ "១ម៉ែត្រ" មានប្រវែងប៉ុណ្ណាពិតប្រាកដ? អស់រយៈពេលជាច្រើនឆ្នាំនេះ យើងអាចរកឃើញចម្លើយ នៅក្នុងមជ្ឈមណ្ឌលឯកសារជាតិបារាំង នៅទីក្រុងប៉ារីស ដែលបានកំណត់យកបន្ទាត់លោហៈមួយ ដែលគេបានបង្កើតតាមរបៀបដ៏ពិសេស ធ្វើជាស្តង់ដាសកល សម្រាប់រង្វាស់ប្រវែង១ម៉ែត្រ។ ដូចនេះ បន្ទាត់ពិសេសនេះ គឺជា "មេបន្ទាត់ម៉ែត្រ" ដែលបន្ទាត់ម៉ែត្រទាំងអស់ត្រូវយកជាខ្នាតគំរូ។

តើមានស្តង់ដាដ៏ឥតខ្ចោះមួយ សម្រាប់កំណត់ថានរណាជា "មនុស្សល្អ"ឬទេ? តើមានមនុស្សដែលល្អឥតខ្ចោះ ដើម្បីធ្វើជាខ្នាតគំរូនៃមនុស្សល្អ ហើយអាចកំណត់ថា អ្វីល្អអ្វីអាក្រក់ឬទេ?

ព្រះគម្ពីរប៊ីប ដែលជាគោលជំនឿរបស់គ្រីស្ទបរិស័ទ បានប្រាប់យើងថា មានតែព្រះអាទិករទេ ដែលជាអង្គបុគ្គល ដែលល្អឥតខ្ចោះ។ យោងតាមព្រះគម្ពីរប៊ីប ព្រះដែលបានបង្កើតរបស់សព្វសារពើ មិនគ្រាន់តែល្អប៉ុណ្ណោះទេ តែថែមទាំងមិនប្រែប្រួល និងល្អឥតខ្ចោះ។ ដូចនេះ មានតែព្រះអង្គទេ ដែលជាស្តង់ដា ឬខ្នាតគំរូដ៏ឥតខ្ចោះ ដែលអាចកំណត់ថា អ្វីល្អ អ្វីអាក្រក់។

ព្រះគម្ពីរក៏បានប្រាប់យើងផងដែរថា ដោយសារព្រះជាម្ចាស់សព្វព្រះទ័យឲ្យយើង បង្ហាញចេញនូវចរិយាសម្បត្តិដ៏ឥតខ្ចោះរបស់ព្រះអង្គ នោះព្រះអង្គក៏បានបង្កើតយើងឲ្យមានសម្បជញ្ញៈ ដើម្បីជួយយើងឲ្យដឹងថា អ្វីត្រូវ អ្វីខុស។ ហេតុនេះហើយបានជាយើងមានការយល់ដឹងពីកំណើត អំពីអ្វីដែលល្អ ទោះយើងមិនតែងតែយល់ច្បាស់អំពីអ្វីដែលល្អក៏ដោយ។

ប៉ុន្តែ អ្នកប្រហែលជាឆ្ងល់ថា តើការស្គាល់ស្តង់ដា ឬខ្នាតគំរូដ៏ឥតខ្ចោះរបស់ព្រះ សម្រាប់ "មនុស្សល្អ" មានប្រយោជន៍អ្វីសម្រាប់យើង? តើយើងអាចធ្វើជាមនុស្សល្អពិតប្រាកដដោយរបៀបណា ពេលដែលក្រមសីលធម៌ដែលយើងបង្កើតដោយខ្លួនឯង មិនអាចឲ្យយើងពឹងផ្អែកបាន ហើយយើងក៏មានភាពមិនល្អឥតខ្ចោះទៀត?

## ការរស់នៅជា "មនុស្សល្អ"

**ឪពុកម្ដាយភាគច្រើន ចង់ឲ្យកូនរបស់ខ្លួនល្អ។** ពួកគេដាក់ស្តង់ដាដ៏ខ្ពស់ សម្រាប់ឲ្យកូនៗរបស់ពួកគេយកជាគំរូ ដោយបង្រៀនពួកគេអំពីរបៀបឈោងឲ្យដល់ស្តង់ដានោះ ហើយក៏ជួយពួកគេ ពេលដែលពួកគេមិនអាចធ្វើ បាន ព្រោះឪពុកម្ដាយស្រឡាញ់កូនរបស់ខ្លួន។

ព្រះដែលជាព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ក៏មានសេចក្តីស្រឡាញ់ ចំពោះយើងផងដែរ ដោយព្រះអង្គសព្វព្រះទ័យឲ្យយើងរស់នៅជាមនុស្សល្អ។ ប៉ុន្តែ ទ្រង់ជ្រាបថា យើងមិនល្អឥតខ្ចោះ ហើយមិនអាចធ្វើជាមនុស្សល្អ ដោយពឹងផ្អែកការប្រឹងប្រែង និងក្រមសីលធម៌របស់ខ្លួនឯងបានឡើយ។ ដូចនេះ ព្រះអង្គក៏បានជួយយើង តាមរបៀបដ៏ពិសេសមួយ។ ព្រះគម្ពីរប៊ីបបានបកស្រាយថា ព្រះអង្គបានចាត់ព្រះរាជបុត្រាព្រះអង្គ ឲ្យយាងចុះមកយកកំណើតជាមនុស្ស នៅក្នុងលោកិយនេះ។ ព្រះរាជបុត្រាព្រះអង្គបានឆ្លងកាត់ទុក្ខវេទនា និងទុក្ខលំបាកដូចយើងរាល់គ្នាដែរ តែព្រះអង្គបានរស់នៅជា "មនុស្សល្អឥតខ្ចោះ" ពោលគឺព្រះអង្គបានរស់នៅតាមរបៀបដែលព្រះវរបិតាសព្វព្រះទ័យ ហើយបានស្តាប់បង្គាប់តាមព្រះវរបិតា ក្នុងការប្រព្រឹត្តគ្រប់យ៉ាងរបស់ព្រះអង្គ។ ព្រះរាជបុត្រានៃព្រះ មានព្រះនាមថា យេស៊ូវ។ ព្រះយេស៊ូវស្រឡាញ់យើង ហើយសព្វព្រះទ័យឲ្យយើង

ក្លាយជាមនុស្សល្អឥតខ្ចោះ ហើយជាទីសព្វព្រះទ័យដល់ព្រះវរបិតា។ ដូចនេះ ព្រះអង្គបានសុគតជំនួសយើង ដោយទទួលយកទោសទាំងអស់ ដែលយើងត្រូវទទួល ដោយសារអំពើបាប និងភាពខ្វះចន្លោះរបស់យើង។

ហេតុនេះហើយ នរណាដែលទទួលជឿព្រះយេស៊ូវ ហើយទទួលស្គាល់ការអ្វីដែលព្រះអង្គបានធ្វើ សម្រាប់យើង អាចទទួលការអត់ទោសបាបពីព្រះអង្គ។ ហើយបើយើងទទួលជឿព្រះយេស៊ូវ នោះព្រះអង្គនឹងប្រទានកម្លាំង ឲ្យយើងអាចជម្នះលក្ខណៈធម្មជាតិរបស់យើង ដែលមានបាប និងមិនល្អឥតខ្ចោះ ហើយដើរតាមស្តង់ដានៃសេចក្ដីល្អឥតខ្ចោះរបស់ព្រះអង្គវិញ។

បន្ទាប់ពីព្រះយេស៊ូវបានសុគតបានបីថ្ងៃ ព្រះអង្គក៏បានមានព្រះជន្មរស់ឡើងវិញ ដោយបង្ហាញថា ព្រះជាម្ចាស់បានទទួលយកការលះបង់របស់ព្រះអង្គហើយ។ គឺដូចដែលព្រះគម្ពីរបានចែងថា

> *"ព្រះគ្រីស្ទទ្រង់បានរងទុក្ខម្តង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ ដោយទ្រង់ត្រូវគេធ្វើគុតខាងសាច់ឈាម តែបានវិញ្ញាណប្រោសឲ្យរស់វិញ"*។-១ពេត្រុស ៣:១៨


ព្រះយេស៊ូវស្រឡាញ់យើង ហើយសព្វព្រះទ័យឲ្យយើង ក្លាយជាមនុស្សល្អឥតខ្ចោះ ហើយជាទីសព្វព្រះទ័យដល់ព្រះវរបិតា។

ខ្ញុំដឹងថា សេចក្តីពិតនេះ អាចធ្វើឲ្យយើងពិបាកយល់ ឬទទួលយក ប៉ុន្តែ ខ្ញុំសង្ឃឹមថា អ្នកនឹងពិចារណាអំពីរឿងនេះជាបន្ថែមទៀត។ មានតែព្រះទេ ដែលជា "មេខ្នាតគំរូ" ដែលអាចកែប្រែយើង ដែលជាមនុស្សមិនល្អឥតខ្ចោះ ហើយធ្វើឲ្យយើងក្លាយជាមនុស្សល្អពិតប្រាកដ។ បើអ្នកឆ្ងល់ថា ខ្លួនអ្នកជាមនុស្សល្អឬអត់ ឬមានអារម្មណ៍ថា អ្នកមិនបានរស់នៅជាមនុស្សល្អ ដូចដែលអ្នករំពឹងចង់បានទេ នោះចូរកុំបាក់ទឹកចិត្ត ឬអស់សង្ឃឹមឡើយ។ ព្រះជាម្ចាស់ស្រឡាញ់អ្នក ហើយព្រះអង្គសព្វព្រះទ័យឲ្យអ្នកអាចធ្វើជាមនុស្សល្អពិតប្រាកដ។

សូមទៅរកមិត្តភក្តិរបស់អ្នក ដែលជាគ្រីស្ទបរិស័ទ ដើម្បីស្វែងយល់បន្ថែមអំពីព្រះយេស៊ូវ។ លោកអ្នកអាចចូលទៅក្នុងវេបសាយ របស់នំម៉ាណាប្រចាំថ្ងៃ ដើម្បីទាញយក កូនសៀវភៅជាច្រើនទៀត តាមLINK: https://khmer-odb.org/ds/។

**Our Daily Bread Ministries**

PO Box 15, Kilsyth, VIC 3137, Australia
Tel: (+61-3) 9761-7086, australia@odb.org
**Our Daily Bread Ministries Ltd**
PO Box 74025, Kowloon Central Post Office, Kowloon, Hong Kong
Tel: (+852) 2626-1102, Fax: (+852) 2626-0216, hongkong@odb.org
**ODB Indonesia**
PO Box 2500, Jakarta 11025, Indonesia
Tel: (+62-21) 2902-8950, Fax: (+62-21) 5435-1975, indonesia@odb.org
**Daily Bread Co. Ltd**
PO Box 46, Ikoma Nara 630-0291, Japan
Tel: (+81-743) 75-8230, Fax: (+81-743) 75-8299, japan@odb.org
**Our Daily Bread Berhad**
PO Box 86, Taman Sri Tebrau, 80057 Johor Bahru, Malaysia
Tel: (+060-7) 353-1718, Fax: (+060-7) 353-4439, malaysia@odb.org
**Our Daily Bread Ministries**
PO Box 303095, North Harbour, Auckland 0751, New Zealand
Tel: (+64-9) 444-4146, newzealand@odb.org
**Our Daily Bread Ministries Asia Ltd**
5 Pereira Road, #07-01 Asiawide Industrial Building, Singapore 368025
Tel: (+65) 6858-0900, Fax: (+65) 6858-0400, singapore@odb.org
**Our Daily Bread Ministries Foundation**
PO Box 47-260, Taipei 10399, Taiwan R.O.C.
Tel: (+886-2) 2585-5340, Fax: (+886-2) 2585-5349, taiwan@odb.org
**Our Daily Bread Ministries Thailand**
PO Box 35, Huamark, Bangkok 10243, Thailand
Tel: (+66-2) 718-5166, Fax: (+66-2) 718-6016, thailand@odb.org